ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.០០៦២.......សហវ.គ.ស.អ.ស.ទ

# សារាចរ
# ស្តីពី
# ការប្រើប្រាស់វិក្កយបត្រអេឡិចត្រូនិកជាកាតព្វកិច្ច តាមប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជាដំណាក់កាលទី១ ជំហានទី២

ស្របតាម "យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១" របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា, ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ និងផែនការសកម្មភាពរួមនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៤, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានដឹកនាំ និងបញ្ចប់ការអភិវឌ្ឍ **ប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា** រួចរាល់ និងបានដាក់ឱ្យដំណើរការជាផ្លូវការកាលពីថ្ងៃទី២២ ខែមករា ឆ្នាំ២០២៥ ជាមួយនឹងការអនុវត្តជាកាតព្វកិច្ចចំពោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងបរិស្ថាន។ ប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា គឺជាប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់រដ្ឋដែលមានតួនាទីជាប្រព័ន្ធកណ្តាលសម្រាប់ផ្លាស់ប្តូរវិក្កយបត្រក្នុងទម្រង់ជាអេឡិចត្រូនិករវាងភាគីអ្នកលក់ ឬអ្នកផ្តល់សេវា និងភាគីអ្នកទិញ ឬអ្នកទទួលសេវា។ ប្រព័ន្ធនេះមានមុខងារក្នុងការផ្តល់អត្តសញ្ញាណ និងបញ្ជាក់ការទទួលស្គាល់វិក្កយបត្រអេឡិចត្រូនិក ជាផ្លូវការដោយមិនតម្រូវឱ្យមានការបោះពុម្ពវិក្កយបត្រជាក្រដាសទៀតឡើយ។ ប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា គឺជាឧបករណ៍សម្រាប់ជំរុញការប្រើប្រាស់វិក្កយបត្រអេឡិចត្រូនិកក្នុងព្រះរាជាណាចក្រកម្ពុជា ដែលសំដៅលើកកម្ពស់តម្លាភាព និងគណនេយ្យភាព នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៤ របស់រដ្ឋាភិបាលកម្ពុជា, ចូលរួមពង្រឹងអនុលោមភាពបទប្បញ្ញត្តិសារពើពន្ធ, ចូលរួមសម្រេចគោលដៅ នៃការអភិវឌ្ឍប្រកបដោយចីរភាព និងត្រៀមខ្លួនចូលរួមកិច្ចសហប្រតិបត្តិការ និងសមាហរណកម្មសេដ្ឋកិច្ចឌីជីថលអាស៊ាន។ ដើម្បីជំរុញការប្រើប្រាស់វិក្កយបត្រអេឡិចត្រូនិក, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដាក់ចេញនូវសារាចរស្តីពីការប្រើប្រាស់វិក្កយបត្រអេឡិចត្រូនិកជាកាតព្វកិច្ច តាមប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជាជាជំហានៗ ដែលចាប់ផ្តើមអនុវត្តចំពោះប្រតិបត្តិការវិក្កយបត្ររវាងក្រុមហ៊ុន ឬអ្នកផ្គត់ផ្គង់ ជាមួយអង្គភាពថវិកាថ្នាក់កណ្តាលក្រោមក្រសួង-ស្ថាប័ន។

សារាចរនេះមានវិសាលភាពចំពោះអង្គភាពថវិកាថ្នាក់កណ្តាល នៃក្រសួងចំនួន ៦(ប្រាំមួយ) គឺ៖ **១-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ២-ក្រសួងពាណិជ្ជកម្ម, ៣-ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, ៤-ក្រសួងអប់រំ យុវជន និងកីឡា, ៥-ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និង ៦-ក្រសួងមុខងារសាធារណៈ** ព្រមទាំងក្រុមហ៊ុន ឬអ្នកផ្គត់ផ្គង់ដែលពាក់ព័ន្ធនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ សារាចរនេះគ្របដណ្តប់លើវិក្កយបត្រសម្រាប់ការស្នើសុំទូទាត់ចំណាយ ដែលឆ្លងកាត់ការអនុវត្តនីតិវិធីកិច្ចលទ្ធកម្មសាធារណៈ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំដល់អង្គភាពថវិកាថ្នាក់កណ្តាល នៃក្រសួងទាំង ៦ (ប្រាំមួយ) ខាងលើ, ក្រុមហ៊ុន ឬអ្នកផ្គត់ផ្គង់នៃក្រសួងទាំងប្រាំមួយ និងស្ថាប័ន ឬអង្គភាពពាក់ព័ន្ធដូចតទៅ៖

ក.អង្គភាពថវិកាថ្នាក់កណ្តាលនៃក្រសួងទាំង ៦(ប្រាំមួយ)

១. ត្រូវទទួលយកតែវិក្កយបត្រអេឡិចត្រូនិកប៉ុណ្ណោះសម្រាប់ការទូទាត់ចំណាយតាមនីតិវិធីលទ្ធកម្មសាធារណៈ។ **វិក្កយបត្រអេឡិចត្រូនិក** សំដៅដល់វិក្កយបត្រដែលបានបញ្ជូនក្នុងទម្រង់ជាអេឡិចត្រូនិកឆ្លងកាត់ការពិនិត្យ និងផ្តល់អត្តសញ្ញាណជាវិក្កយបត្រអេឡិចត្រូនិកដោយប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា។

២. ត្រូវផ្តល់ដំណឹងទៅក្រុមហ៊ុន ឬអ្នកផ្គត់ផ្គង់របស់ខ្លួនឱ្យចុះឈ្មោះចូលជាសមាជិកនៃប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា ដើម្បីប្រើប្រាស់វិក្កយបត្រជាទម្រង់អេឡិចត្រូនិក ក្នុងករណីមិនទាន់ក្លាយជាសមាជិក។

៣. អង្គភាពថវិកាថ្នាក់កណ្តាលនៃក្រសួងទាំង ៦(ប្រាំមួយ) នឹងក្លាយជាសមាជិកនៃប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជាដោយស្វ័យប្រវត្តិ។ អង្គភាពថវិកាថ្នាក់កណ្តាលនីមួយៗត្រូវចាត់តាំងតំណាងក្នុងការគ្រប់គ្រងព័ត៌មានសមាជិកភាព របស់ខ្លួននៅក្នុងប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា តាមរយៈផតថលវិក្កយបត្រអេឡិចត្រូនិកកម្ពុជា ព្រមទាំងអាចទទួលវិក្កយបត្រអេឡិចត្រូនិកពីក្រុមហ៊ុន ឬអ្នកផ្គត់ផ្គង់តាមរយៈផតថលនេះ។ ការចាត់តាំងតំណាង គឺត្រូវបញ្ជូនលិខិតផ្លូវការទៅប្រតិបត្តិករនៃប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា។ ក្នុងអំឡុងពេលដែលប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជាមិនទាន់បានភ្ជាប់ និងដាក់ដំណើរការសន្ទានកម្មជាមួយប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អង្គភាពថវិកាថ្នាក់កណ្តាលអាចប្រើប្រាស់វិក្កយបត្រអេឡិចត្រូនិកនោះទៅអនុវត្តនីតិវិធីទូទាត់បន្តដូចការអនុវត្តបច្ចុប្បន្ន។

ខ.ក្រុមហ៊ុន ឬ អ្នកផ្គត់ផ្គង់

១. ការចេញវិក្កយបត្រទៅអង្គភាពថវិកាថ្នាក់កណ្តាលនៃក្រសួងទាំង ៦(ប្រាំមួយ) ខាងលើ ត្រូវតែជាវិក្កយបត្រអេឡិចត្រូនិក។

២. ត្រូវចុះឈ្មោះជាសមាជិកនៃប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា ដើម្បីអាចប្រើប្រាស់ប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជាបាន។ ការចុះឈ្មោះជាសមាជិកត្រូវអនុវត្តតាមវិធាន និងនីតិវិធីការចូលជាសមាជិកនៃប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា។

៣. វិក្កយបត្រអេឡិចត្រូនិកអាចបង្កើតចេញតាមរយៈផតថលវិក្កយបត្រអេឡិចត្រូនិកកម្ពុជា ឬប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការចេញវិក្កយបត្រណាមួយ ដែលបានចុះបញ្ជីទទួលស្គាល់ និងបានភ្ជាប់ដំណើរការសន្ទានកម្ម រួចរាល់ជាមួយនឹងប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា។

គ.អគ្គនាយកដ្ឋានពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

១. អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល ត្រូវដើរតួនាទីជាប្រតិបត្តិករនៃប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា។

២. អគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានរតនាគារជាតិ ត្រូវចូលរួមពិនិត្យ និងពង្រឹងលើការប្រើប្រាស់វិក្កយបត្រអេឡិចត្រូនិក នៅក្នុងវិហរនីតិវិធីសម្រាប់ការស្នើទូទាត់ចំណាយរបស់អង្គភាពថវិកាថ្នាក់កណ្តាលនៃក្រសួងទាំង ៦(ប្រាំមួយ)ដែលតម្រូវឱ្យអង្គភាពស្នើទូទាត់តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ភ្ជាប់មកជាមួយបន្ថែមនូវវិក្កយបត្រអេឡិចត្រូនិក។ ករណីពិនិត្យឃើញថាវិក្កយបត្រអេឡិចត្រូនិកដែលភ្ជាប់មកមិនអាចផ្ទៀងផ្ទាត់ជាមួយប្រព័ន្ធវិក្កយបត្រអេឡិចត្រូនិកកម្ពុជា អគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានរតនាគារជាតិអាចធ្វើការបដិសេធបាន ហើយត្រូវជូនដំណឹងទៅអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថលដើម្បីមានវិធានការបន្ត។ ក្នុងដំណាក់កាលអន្តរកាល, ចំពោះវិក្កយបត្រដែលមិនទាន់បានរៀបចំតាមប្រព័ន្ធវិក្កយបត្រ

អេឡិចត្រូនិកកម្ពុជា អគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានរតនាគារជាតិ អាចធ្វើការទូទាត់ដោយផ្អែកតាមលិខិតយុត្តិការចំណាយដែលមានការបញ្ជាក់ទទួលស្គាល់ពីអាណាប័ក។

ទទួលបានសារាចរនេះ គ្រប់អង្គភាពពាក់ព័ន្ធ ដែលស្ថិតក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងពាណិជ្ជកម្ម, ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និង ក្រសួងមុខងារសាធារណៈ ព្រមទាំងភាគីពាក់ព័ន្ធត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៤ រោច ខែ អាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០២៥

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ*
- *ខុទ្ទកាល័យ សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*